# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៤៤១ អយក.ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកម្រិតសមមូលវិញ្ញាបនបត្រ
## កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៥៤ ក.ប/ប្រ.ក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួល និងអនុវត្តការអភិវឌ្ឍជំនាញការអប់រំ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការតម្រង់ទិសវិជ្ជាជីវៈ រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញប្រកាសអន្តរក្រសួងលេខ ៩៦២ អយក.ប្រក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីដឹកនាំ សម្របសម្រួល និងអនុវត្តកម្មវិធីសិក្សាកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៤៣៧ អយក.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសអន្តរក្រសួងនេះមានគោលបំណងកំណត់ការកម្រិតសមមូលវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត។

**ប្រការ២ .-**

ប្រកាសអន្តរក្រសួងនេះមានគោលដៅកំណត់អំពី៖

- ប្រភេទ ទម្រង់ និងតម្លៃសមមូលនៃវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត
- ការផ្តល់ ការប្រើប្រាស់ និងការដកហូតវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត។

**ប្រការ៣ .-**

ប្រកាសអន្តរក្រសួងនេះមានវិសាលភាពអនុវត្តលើវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិតដែលផ្តល់ជូនដោយមណ្ឌលសិក្សាប៊ីបតាមកម្មវិធីប៊ីប ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី២

## ផ្នែកទី១

## ប្រភេទ ទម្រង់ និងកម្រិតសមមូលនៃវិញ្ញាបនបត្របន្ទាប់ការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីប

**ប្រការ៤ .-**

វិញ្ញាបនបត្របន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីបមានតម្លៃសមមូលនឹងវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ។

វិញ្ញាបនបត្របន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីបត្រូវចុះហត្ថលេខាដោយនាយកមណ្ឌលសិក្សាប៊ីបនៅផ្នែកខាងស្តាំ និងចុះហត្ថលេខាដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សាមី នៅផ្នែកខាងឆ្វេង សម្រាប់មណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡា។

លក្ខណៈសម្គាល់និងទម្រង់នៃវិញ្ញាបនបត្របន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីបដែលផ្តល់ជូនដោយមណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡាជាឧបសម្ព័ន្ធទី១នៃប្រកាសអន្តរក្រសួងនេះ។

វិញ្ញាបនបត្របន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីប ត្រូវចុះហត្ថលេខាដោយនាយកមណ្ឌលសិក្សាប៊ីបនៅផ្នែកខាងឆ្វេង និងចុះហត្ថលេខាដោយអគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅផ្នែកខាងស្តាំ សម្រាប់មណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ទម្រង់នៃវិញ្ញាបនបត្របន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីបដែលផ្តល់ជូនដោយមណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាឧបសម្ព័ន្ធទី២នៃប្រកាសអន្តរក្រសួងនេះ។

## ផ្នែកទី២

## ការផ្តល់ ការប្រើប្រាស់ និងការដកហូតវិញ្ញាបនបត្រ<br>បន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីប

**ប្រការ៥ .-**

អ្នកសិក្សាដែលបានបញ្ចប់ការសិក្សាតាមគោលការណ៍កំណត់និងបានប្រឡងជាប់ជាស្ថាពរនឹងទទួលបានវិញ្ញាបនបត្របន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីប ហើយអាចដាក់ពាក្យស្នើសុំចូលរៀនសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ស្របតាមអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា នៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសនៃក្រសួងអប់រំ យុវជន និងកីឡា ឬយកទៅប្រើប្រាស់តាមការដែលអាចប្រើបាន។

**ប្រការ៦ .-**

វិញ្ញាបនបត្របន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីបនឹងត្រូវបានដកហូតពីអ្នកសិក្សា ឬអ្នកប្រើប្រាស់ក្នុងករណីរកឃើញថា អ្នកសិក្សាមិនបានបំពេញគ្រប់លក្ខខណ្ឌតាមគោលការណ៍កំណត់ ឬមានការក្លែងបន្លំផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់និងការផ្តល់វិញ្ញាបនបត្រ។

## ជំពូកទី៣

## ផ្នែកទី១

## ប្រភេទ ទម្រង់ និងកម្រិតសមមូលនៃវិញ្ញាបនបត្រ
## វិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីប

**ប្រការ៧ .-**

វិញ្ញាបនបត្រវិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីបមានតម្លៃសមមូលនឹងវិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិ ឬ វិញ្ញាបនបត្រវិជ្ជាជីវៈស្របតាមអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្ដីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។

វិញ្ញាបនបត្រវិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីបត្រូវចុះហត្ថលេខាដោយនាយកមណ្ឌលសិក្សាប៊ីបនៅផ្នែកខាងស្ដាំ និងចុះហត្ថលេខាដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមី នៅផ្នែកខាងឆ្វេង សម្រាប់មណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡា។

លក្ខណៈសម្គាល់និងទម្រង់នៃវិញ្ញាបនបត្រវិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីប ដែលផ្ដល់ជូនដោយមណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡាជាឧបសម្ព័ន្ធទី៣នៃប្រកាសអន្តរក្រសួងនេះ។

វិញ្ញាបនបត្រវិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីបត្រូវចុះហត្ថលេខាដោយនាយកមណ្ឌលសិក្សាប៊ីបនៅផ្នែកខាងឆ្វេង និងចុះហត្ថលេខាដោយអគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅផ្នែកខាងស្ដាំ សម្រាប់មណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

ទម្រង់នៃវិញ្ញាបនបត្រវិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីបដែលផ្ដល់ជូនដោយមណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈជាឧបសម្ព័ន្ធទី៤នៃប្រកាសអន្តរក្រសួងនេះ។

## ផ្នែកទី២

## ការផ្ដល់ ការប្រើប្រាស់ និងការដកហូតវិញ្ញាបនបត្រ
## វិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីប

**ប្រការ៨ .-**

អ្នកសិក្សាដែលបានបញ្ចប់ការសិក្សាតាមគោលការណ៍កំណត់និងបានប្រឡងជាប់ជាស្ថាពរនឹងទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីប ហើយអាចដាក់ពាក្យស្នើសុំចូលរៀនសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ស្របតាមអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្ដីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា នៅតាមគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬយកទៅប្រើប្រាស់តាមការដែលអាចប្រើបាន។

**ប្រការ៩ .-**

វិញ្ញាបនបត្រវិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីបនឹងត្រូវបានដកហូតពីអ្នកសិក្សា ឬអ្នកប្រើប្រាស់ក្នុងករណីរកឃើញថា អ្នកសិក្សាមិនបានបំពេញគ្រប់លក្ខខណ្ឌតាមគោលការណ៍កំណត់ ឬមានការក្លែងបន្លំផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់និងការផ្តល់វិញ្ញាបនបត្រ។

## ជំពូកទី៤

## ផ្នែកទី១

## ប្រភេទ ទម្រង់ និងកម្រិតសមមូលនៃវិញ្ញាបនបត្រ វិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប)

**ប្រការ១០ .-**

វិញ្ញាបនបត្រវិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប) មានតម្លៃសមមូលនឹងវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ។

វិញ្ញាបនបត្រវិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប) ត្រូវចុះហត្ថលេខាដោយនាយកមណ្ឌលសិក្សាប៊ីបនៅផ្នែកខាងស្តាំ និងចុះហត្ថលេខាដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តសាមី នៅផ្នែកខាងឆ្វេង សម្រាប់មណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡា។

លក្ខណៈសម្គាល់និងទម្រង់នៃវិញ្ញាបនបត្រវិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប) ដែលផ្តល់ជូនដោយមណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡាជាឧបសម្ព័ន្ធទី៥នៃប្រកាសអន្តរក្រសួងនេះ។

វិញ្ញាបនបត្រវិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប) ត្រូវចុះហត្ថលេខាដោយនាយកមណ្ឌលសិក្សាប៊ីបនៅផ្នែកខាងឆ្វេង និងចុះហត្ថលេខាដោយអគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅផ្នែកខាងស្តាំ សម្រាប់មណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ទម្រង់នៃវិញ្ញាបនបត្រវិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប) ដែលផ្តល់ជូនដោយមណ្ឌលសិក្សាប៊ីបដែលទទួលស្គាល់និងអនុញ្ញាតឱ្យបើកដំណើរការដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាឧបសម្ព័ន្ធទី៦នៃប្រកាសអន្តរក្រសួងនេះ។

## ផ្នែកទី២

## ការផ្តល់ ការប្រើប្រាស់ និងការដកហូតវិញ្ញាបនបត្រ វិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប)

**ប្រការ១១ .-**

អ្នកសិក្សាដែលបានបញ្ចប់ការសិក្សាតាមគោលការណ៍កំណត់ និងបានប្រឡងជាប់ជាស្ថាពរ នឹងទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប) ហើយអាចដាក់ពាក្យស្នើសុំចូលរៀនសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ស្របតាមអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា នៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស



៖ង.ធ

នៃក្រសួងអប់រំ យុវជន និងកីឡា ឬគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយកទៅប្រើប្រាស់តាមការដែលអាចប្រើបាន។

**ប្រការ១២ .-**

វិញ្ញាបនបត្រវិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប) នឹងត្រូវបានដកហូតពីអ្នកសិក្សា ឬអ្នកប្រើប្រាស់ក្នុងករណីរកឃើញថា អ្នកសិក្សាមិនបានបំពេញគ្រប់លក្ខខណ្ឌតាមគោលការណ៍កំណត់ ឬមានការក្លែងបន្លំផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់និងការផ្តល់វិញ្ញាបនបត្រ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ដូចប្រការ ១៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ អគ្គ.យុវជន អ.យ.ក

**ឧបសម្ព័ន្ធទី១** នៃប្រកាសអន្តរក្រសួងលេខៈ ៤៤១ អយក.ប្រ.ស៊ុះ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២១
ស្ដីពីការកម្រិតសមមូលវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡា......................**

**វិញ្ញាបនបត្រ**
**បន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីប**
**Skills Bridging Certificate for Technical High School through the Basic Education Equivalency Programme (BEEP)**

**បញ្ជាក់ថា៖**
**Certifies that:**

ឈ្មោះ..................................................................ភេទ...............
សញ្ជាតិ..........................ថ្ងៃខែឆ្នាំកំណើត................................
បានប្រឡងជាប់ជាស្ថាពរក្នុងកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប) ដើម្បីបន្តការសិក្សានៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។
សម័យប្រឡង ៖..................................................................
នៅមណ្ឌលសិក្សា ៖..................................................................
ថ្ងៃ............................ខែ...........ឆ្នាំ................ព.ស.២៥.....
រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ................ឆ្នាំ២០.......

**ប្រធាន**
**មន្ទីរអប់រំ យុវជន និងកីឡា...............................**

លេខ:...................

រូបថត
4 x 6

Name.............................................................Sex................
Nationality.............................Date of Birth............................
Has successfully completed the skills bridging course through **the Basic Education Equivalency Programme (BEEP)** to pursue further training at the Technical High School.
Exam date ..................................................................
Learning Center...........................................................

Date......................................
**នាយកមណ្ឌលសិក្សាប៊ីប**
**Director of Learning Center**

**ឧបសម្ព័ន្ធទី២** នៃប្រកាសអន្តរក្រសួងលេខ: ៤៩១ ការ.ប.ក ចុះថ្ងៃទី ១៩ ខែ មីនា ...... ឆ្នាំ២០២១
ស្តីពីការកម្រិតសមមូលវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធីណិត

**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
ជាតិ សាសនា ព្រះមហាក្សត្រ
**NATION RELIGION KING**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**MINISTRY OF LABOUR AND VOCATIONAL TRAINING**

## វិញ្ញាបនបត្របន្តការសិក្សានៅវិទ្យាល័យបច្ចេកទេសតាមកម្មវិធីប៊ីប
## SKILLS BRIDGING CERTIFICATE FOR TECHNICAL HIGH SCHOOL THROUGH BASIC EDUCATION EQUIVALENCY PROGRAMME
**(ឈ្មោះគ្រឹះស្ថាន អ.ប.វ./អង្គការ/សហគ្រាស គ្រឹះស្ថាន)**
**(NAME OF INSTITUTION/ORGANIZATION/ENTERPRISE)**

This is to certify that ..............................
Sex .................... Nationality ..............................
Date of Birth ..............................
Has successfully completed **the skills bridging course through the Basic Education Equivalency Programme (BEEP)** to pursue further training at the technical high school.
Exam date : ..............................
At : ..............................

បញ្ជាក់ថា ..............................
ភេទ .................... សញ្ជាតិ ..............................
កើតថ្ងៃទី .................... ខែ .................... ឆ្នាំ ....................
បានចូលរៀន និងបញ្ចប់ដោយជោគជ័យក្នុង **កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធីណិត (ប៊ីប)** ដើម្បីបន្តការសិក្សានៅវិទ្យាល័យបច្ចេកទេស។
សម័យប្រឡង : ..............................
នៅ : ..............................

ថ្ងៃ.................... ខែ.............. ឆ្នាំ.................... ព.ស. ..............
................, ........../ ........../ ..........  លេខ..........  រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........... ឆ្នាំ.............

**នាយក/នាយិកា**
**DIRECTOR**

**អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**
**DIRECTOR GENERAL OF TVET**

4 x 6

**ឧបសម្ព័ន្ធទី៣** នៃប្រកាសអន្តរក្រសួងលេខ: ៤៤១ អយក.ប្រក: ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២១
ស្តីពីការកម្រិតសមមូលវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡា........................**

## វិញ្ញាបនបត្រ
## វិជ្ជាជីវៈស្ពានចម្លងបន្តជំនាញតាមកម្មវិធីប៊ីប
**Vocational Certificate of Skills Bridging of the Basic Education Equivalency Programme (BEEP)**

**បញ្ជាក់ថា៖**
**Certifies that:**

ឈ្មោះ.................................................................ភេទ..............
សញ្ជាតិ.........................ថ្ងៃខែឆ្នាំកំណើត.................................
បានប្រឡងជាប់ជាស្ថាពរ ក្នុងកម្មវិធីស្ពានចម្លងបន្តជំនាញតាមកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប)។
សម័យប្រឡង ៖..................................................................
នៅមណ្ឌលសិក្សា ៖..............................................................
ថ្ងៃ............................ខែ...........ឆ្នាំ................ព.ស.២៥....
រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ................ឆ្នាំ២០.......

**ប្រធាន**
**មន្ទីរអប់រំ យុវជន និងកីឡា...............................**

លេខ:....................

រូបថត
4 x 6

Name.........................................................................Sex.................
Nationality..............................Date of Birth...........................
Has successfully completed the skills bridging of the **Basic Education Equivalency Programme (BEEP).**
Exam date ..........................................................................
Learning Center...................................................................
Date.........................................

**នាយកមណ្ឌលសិក្សាប៊ីប**
**Director of Learning Center**

២.

**ឧបសម្ព័ន្ធទី៤** នៃប្រកាសអន្តរក្រសួងលេខ:...៤៤១ ការ.ប/ប្រក...ចុះថ្ងៃទី...១៩... ខែ...មីនា......ឆ្នាំ២០២១
ស្តីពីការកម្រិតសមមូលវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត

**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
ជាតិ សាសនា ព្រះមហាក្សត្រ
**NATION RELIGION KING**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**MINISTRY OF LABOUR AND VOCATIONAL TRAINING**

## វិញ្ញាបនបត្រវិជ្ជាជីវៈស្ពានចម្លងបំណិនតាមកម្មវិធីប៊ីប
**VOCATIONAL CERTIFICATE OF SKILL BRIDGING OF BEEP**
**(ឈ្មោះគ្រឹះស្ថាន អ.ប.វ./អង្គការ/សហគ្រាស គ្រឹះស្ថាន)**
**(NAME OF INSTITUTION/ORGANIZATION/ENTERPRISE)**

This is to certify that ................................................
Sex ..................... Nationality ...................................
Date of Birth ...............................................................
Has successfully completed **Skill Bridging of the Basic Education Equivalency Programme (BEEP).**
Exam date : ..................................................................
At : ................................................................................

បញ្ជាក់ថា ...................................................................
ភេទ ................................ សញ្ជាតិ ...................................
កើតថ្ងៃទី ........................ ខែ ........................ ឆ្នាំ ........................
បានចូលរៀន និងបញ្ចប់ដោយជោគជ័យក្នុង **កម្មវិធីស្ពានចម្លងបំណិនតាមកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប)**។
សម័យប្រឡង ៖ ..................................................................
នៅ ៖ ...........................................................................

ថ្ងៃ.......................... ខែ.............. ឆ្នាំ.................... ព.ស. ...........
............., ........../ ........../..........  លេខ..........  រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........... ឆ្នាំ..............

**នាយក/នាយិកា**
**DIRECTOR**

**អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**
**DIRECTOR GENERAL OF TVET**

4 x 6

**ឧបសម្ព័ន្ធទី៥** នៃប្រកាសអន្តរក្រសួងលេខ ៤៤៧ អយក.ប្រក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២១
ស្តីពីការកម្រិតសមមូលវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡា**........................

**វិញ្ញាបនបត្រ**
**វិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត ( ប៊ីប )**
**Vocatinal Certificate of the Basic Education Equivalency Programme (BEEP)**

**បញ្ជាក់ថា៖**
**Certifies that:**

ឈ្មោះ:.......................................................................ភេទ..............
សញ្ជាតិ..........................ថ្ងៃខែឆ្នាំកំណើត................................
បានប្រឡងជាប់ជាស្ថាពរក្នុងកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត(ប៊ីប)។
សម័យប្រឡង ៖............................................................
នៅមណ្ឌលសិក្សា ៖............................................................
ថ្ងៃ............................ខែ...........ឆ្នាំ.................ព.ស.២៥....
រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ................ឆ្នាំ២០........

**ប្រធាន**
**មន្ទីរអប់រំ យុវជន និងកីឡា**..............................

Name.......................................................................Sex................
Nationality..............................Date of Birth............................
Has successfully completed the **Basic Education Equivalency Programme (BEEP)**.
Exam date ..............................................................
Learning Center...........................................................
Date.................................

លេខ:.....................

**នាយកមណ្ឌលសិក្សាប៊ីប**
**Director of Learning Center**

រូបថត
4 x 6

ស.

**ឧបសម្ព័ន្ធទី៦** នៃប្រកាសអន្តរក្រសួងលេខ...២៤១ ការប.(ប.ក)...ចុះថ្ងៃទី...១៩...ខែ...មីនា....ឆ្នាំ២០២១

ស្តីពីការកម្រិតសមមូលវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត

**ព្រះរាជាណាចក្រកម្ពុជា**
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
MINISTRY OF LABOUR AND VOCATIONAL TRAINING

**វិញ្ញាបនបត្រវិជ្ជាជីវៈកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត ( ប៊ីប )**
**VOCATIONAL CERTIFICATE OF THE BASIC EDUCATION EQUIVALENCY PROGRAMME (BEEP)**
**(ឈ្មោះគ្រឹះស្ថាន អ.ប.វ./អង្គការ/សហគ្រាស គ្រឹះស្ថាន )**
**(NAME OF INSTITUTION/ORGANIZATION/ENTERPRISE)**

This is to certify that ..........................................................

Sex ...................... Nationality ..........................................

Date of Birth ..........................................................................

Has successfully completed **The Basic Education Equivalency Programme (BEEP).**

Exam date : ..............................................................................

At : ..........................................................................................

បញ្ជាក់ថា ..........................................................................

ភេទ ...................................សញ្ជាតិ .......................................

កើតថ្ងៃទី ............................ខែ ............................ឆ្នាំ ..........................

បានចូលរៀន និងបញ្ចប់ដោយជោគជ័យក្នុង **កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត ( ប៊ីប )**។

សម័យប្រឡង : ..........................................................................

នៅ : ........................................................................................

ថ្ងៃ.............................. ខែ.............. ឆ្នាំ...................... ព.ស. .............

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........... ឆ្នាំ...........

..................., ............../ ............. /.............

**នាយក/នាយិកា**
DIRECTOR

លេខ...........

**អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**
DIRECTOR GENERAL OF TVET

4 x 6